# សេចក្តីថ្លែងការណ៍

តំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី ១៧៩១នៃសំណុំរឿង០០២
សូមសម្តែងនូវក្តីព្រួយបារម្ភអំពីការបំបែកកិច្ចដំណើការនីតិវិធី និងការមិនអនុញ្ញាតិឲ្យ
មេធាវីតំណាងដើមបណ្តឹងធ្វើកំណាត់សម្គាល់ក្នុងដំណាក់កាលដំបូងនៃសវនាលើអង្គសេចក្តី

***ភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១១:*** យើងបានទទួលដំណឹង អំពីដំណើរការបំបែកនីតិវិធីថ្ងៃនេះ ដែលដីកានេះបានដាក់កំរិតទៅលើការពិនិត្យពិច័យតែទៅលើអង្គហេតុ ២ គឺការជម្លៀសប្រជាជនដោយបង្ខំ ។ ដោយពិចារណាទៅលើអាយុរបស់ជនជាប់ចោទ យើងគាំទ្រដំណើរការបំបែកនីតិវិធី ដើម្បីជំនុំជំរះផ្តន្ទាទោសឲ្យបានឆាប់ ប៉ុន្តែមិនសប្បាយចិត្តចំពោះការជ្រើសរើសដោយកម្រិតអំពីបទឧក្រិដ្ឋ ។ វាមិនសមស្របទៅនឹងចំនួនដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងគ្រោះពីព្យសនកម្ម និងទិដ្ឋភាពពិតនៃឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិប្បតេយ្យ ។ ដូចនេះ យើងខ្ញុំសូមអំពាវនាវឲ្យអង្គជំនុំជំរះ ពិចារណាលើដំណើការបំបែកនីតិវិធីក្នុងពេលបច្ចុប្បន្ន វានឹងដកចេញនូវចំនួនដើមបណ្តឹងរដ្ឋប្បវេណី ៧៥ភាគរយនៃដើមបណ្តឹងសរុបទាំងអស់ក្នុងសំណុំរឿងនេះ ។

បន្ថែមពីនេះ យើងកត់សម្គាល់ឃើញថា ដំណាក់កាលដំបូងនៃសវនាលើអង្គសេចក្តី សិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យធ្វើការកត់សម្គាល់ ផ្ទុយទៅវិញភាគីសហព្រះរាជអាជ្ញា អាចធ្វើសេចក្តីសន្និដ្ឋាន និងមានសេចក្តីថ្លែងការណ៍ឆ្លើយតបពីភាគីការពារជនជាប់ចោទ ។ ប៉ុន្តែសំណើសុំធ្វើសេចក្តីសន្និដ្ឋានបើកក្នុងដំណាក់កាលដំបូងនេះត្រឹមតែ ៣០នាទីប៉ុណ្ណោះ ត្រូវបានអង្គជំនុំជំរះសាលាដំបូងបដិសេធ ។

ហេតុដូចនេះ វានឹងមិនមានសម្លេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលដំបូងនៃនីតិវិធីនេះឡើយ និងធ្វើឲ្យយើងខ្ញុំមិនសប្បាយចិត្តពីការសំរេចនេះឡើយ ។

យើងខ្ញុំ សូមស្នើឲ្យអង្គជំនុំជំរះសាលាដំបូង ពិចារណាឡើងវិញលើសេចក្តីសំរេចរបស់ខ្លួន និងពិចារណាផ្តល់ឪកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិធ្វើសេចក្តីកត់សម្គាល់ក្នុងដំណាក់កាលដំបូងនេះ ។

*ព័ត៌មានបន្ថែម សូមទំនាក់ទំនង:*

Mr. LATT Ky (ADHOC) +855 (0)12828411